# ការប្រឡងតេស្តរបស់រដ្ឋ 2012

## សូមជម្រាបមកដល់មាតាបិតា និងអ្នកអាណាព្យាបាលរបស់សិស្ស សូមជ្រាប៖

នៅរាល់រដូវស្លឹកឈើលាស់, រដ្ឋតម្រូវឲ្យសិស្សទាំងអស់ក្នុងថ្នាក់ទី3-8 និងទី10 ប្រឡងតេស្ត ដើម្បីធានាថា សិស្សទាំងអស់ទទួលបាននូវការសិក្សាត្រឹមត្រូវ ទៅតាមបទដ្ឋានសិក្សា។ លទ្ធផលនៃការប្រឡងតេស្តនេះមានសារសំខាន់ណាស់សម្រាប់យើងទាំងអស់គ្នា។

សិស្សនៅថ្នាក់ទី 3-8 ត្រូវតែប្រឡងតេស្តវង្វាស់នៃការចម្រើនលូតលាស់របស់សិស្ស **(MSP)**។ សិស្សនៅកម្រិតវិទ្យាល័យត្រូវប្រឡងសម្បទាមធ្យមសិក្សាទុតិយភូមិ **(HSPE)**។ មិនតែប៉ុណ្ណោះ កាលពីពីឆ្នាំមុនរដ្ឋបានចាប់ផ្តើមឲ្យមានការប្រឡងមុខ បញ្ចប់ថ្នាក់ សម្រាប់វិញ្ញាសារពិជគណិតទី1 និងធរណីមាត្រ ហើយនឹងត្រូវចាប់ផ្តើមដំបូងផ្នែក វិញ្ញាសាជីវវិទ្យា EOC ក្នុងរដូវស្លឹកឈើលាស់ ឆ្នាំ 2012។

ការប្រឡង MSP ក៏ត្រូវបានផ្តល់ជូនតាមអ៊ិនធឺណិត សម្រាប់វិញ្ញាសារអំណាន, គណិតសាស្ត្រ និង វិទ្យាសាស្ត្រ (ថ្នាក់ទី 5 និង 8)។ ដោយចាប់ផ្តើមពីរដូវស្លឹកឈើលាស់ឆ្នាំ 2012 , សិស្សថ្នាក់ទី 3-8 អាចប្រឡងវិញ្ញាសាអាន និងគណិតសាស្ត្រតាមកុំព្យូទ័របាន ។

តេស្តរបស់រដ្ឋយើងត្រូវបានគេដាក់ឈ្មោះ ដើម្បីបញ្ជាក់អំពីគោលដៅជាក់លាក់របស់វា។

ការប្រឡង MSP *ប្រឡងតេស្តវង្វាស់នៃការចម្រើនលូតលាស់របស់សិស្ស* ។ ដោយហេតុតែលទ្ធផលនៃការប្រឡង MSP សំខាន់ ការប្រឡងផ្នែករដ្ឋមិន គួរជាការវាស់ជំនាញ និង ចំណេះដឹងរបស់សិស្សនោះទេ ។ សកម្មភាពសិក្សាទាំងស្រុងរបស់សិស្សគួរតែត្រូវបានលើកយកមកពិចារណាជានិច្ច ។

តេស្តHSPE គឺដើម្បីធានាថា សិស្សមធ្យមសិក្សាទុតិយភូមិមាន*សម្បទា,* ឬមានជំនាញជាមូលដ្ឋានចាំបាច់ ដើម្បីឈានទៅកាន់ដំណាក់កាលខាងមុខៗទៀតក្នុងជីវិតរបស់ពួកគេ។ តេស្តមធ្យមសិក្សាទុតិយភូមិគឺជាតេស្ត ដែលផ្តោតលើលក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សា។

សិស្សរៀន**ឆ្នាំសិក្សា 2012** ត្រូវតែប្រឡងជាប់វិញ្ញាសាអំនាន និងសរសេរ នៅផ្នែក វិញ្ញាសាតាមជំរើសផ្សេ ដែលអនុម័តទទួលស្គាល់ ដោយរដ្ឋ ឬការវាយតម្លៃសិស្សក្នុងកម្មវិធីអប់រំ ពិសេស **និង** ប្រឡងជាប់វិញ្ញាសាគណិតសាស្ត្រ ឬត្រូវរៀនមុខវិជ្ជាគណិតសាស្ត្រឲ្យបាន ពីរក្រេឌីតបន្ទាប់ពីថ្នាក់ទី **10** ។

សិស្សសិក្សាក្នុងឆ្នាំសិក្សា **2013** និង **2014** ត្រូវតែប្រឡងជាប់វិញ្ញាសា អំនាន សរសេរ និងគណិតសាស្ត្រ ដើម្បីទើបអាចបញ្ចប់ការសិក្សាបាន។ សិស្សសិក្សាក្នុងឆ្នាំសិក្សា **2015** តទៅ ត្រូវតែប្រឡងជាប់វិញ្ញាសាអាន សរសេរ គណិតសាស្ត្រ និងវិទ្យាសាស្ត្រ។

បើលោកអ្នកមានសំណួរ ឬចំណាប់អារម្មអំពីការរៀនសូត្ររបស់កូនលោកអ្នក, សូមទាក់ទងទៅគ្រូរបស់កូនលោកអ្នក ឬអ្នកផ្តល់ឱវាទផ្នែកសិក្សាអប់រំប្រចាំសាលារបស់កូនលោកអ្នក។ ដើម្បីស្វែងយល់ព័ត៌មានបន្ថែមស្តីពីប្រព័ន្ធតេស្តរបស់រដ្ឋ, សូមចូលទៅអានមើលព័ត៌មានលើគេហទំព័រ **www.WAtesting.com** ។

## តើនរណាខ្លះត្រូវប្រឡង ហើយតើត្រូវប្រឡងនៅពេលណា?

ច្បាប់ No Child Left Behind Act (គ្មានកុមារណាម្នាក់ត្រូវទុកឲ្យនៅក្រោយគេ) របស់រដ្ឋាភិបាលសហព័ន្ធតម្រូវឲ្យសិស្សគ្រប់រូបក្នុងថ្នាក់ទី3-8 និងទី10 ប្រឡងមុខវិជ្ជារៀនអាន និងមុខវិជ្ជាគណិតសាស្ត្រ, និងបីថ្នាក់ទៀត (គឺថ្នាក់ទី5, 8 និងទី10) ប្រឡងមុខវិជ្ជាវិទ្យាសាស្ត្រជារៀងរាល់ឆ្នាំ។ រដ្ឋរបស់យើងក៏ តម្រូវឲ្យសិស្ស (ថ្នាក់ទី4, 7 និងទី10) ប្រឡងមុខវិជ្ជារៀនសរសេរផងដែរ។ រដ្ឋរបស់យើងក៏ថែមទាំងមានវិញ្ញាសាប្រឡងតាមបណ្តាញអ៊ិនធឺណិតទៀតផង។

| ថ្នាក់ | ទី3 | ទី4 | ទី5 | ទី6 | ទី7 | ទី8 | ទី9 | ទី10 | ទី11 | ទី12 |
|---|---|---|---|---|---|---|---|---|---|---|
| រៀនអាន | ✓■ | ✓■ | ✓■ | ✓■ | ✓■ | ✓■ | NT | ✓ | *ចាំបាច់តែនៅពេលណាសិស្សមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សា។* | |
| គណិតសាស្ត្រ | ✓■ | ✓■ | ✓■ | ✓■ | ✓■ | ✓■ | ✓ | ✓ | | |
| រៀនសរសេរ | | ✓ | | | ✓ | | NT | ✓ | | |
| វិទ្យាសាស្ត្រ | | | ✓■ | | | ✓■ | ✓ | ✓ | | |

■ បើកឲ្យប្រឡងតាមបណ្តាញអ៊ិនធឺណិតនៅក្នុងរដូវស្លឹកឈើលាស់2012

NT ប្រធានបទមិនត្រូវបានតម្រូវឲ្យប្រឡង (សម្រាប់តែសិស្សក្នុងថ្នាក់ទី9 ដែលត្រូវប្រឡងវិញ្ញាសាបញ្ចប់ការសិក្សាមុខវិជ្ជាគណិតសាស្ត្រប៉ុណ្ណោះ)

## កាលវិភាគនៃការប្រឡងតេស្ត និងរបាយការណ៍តេស្តរបស់រដ្ឋ សម្រាប់ឆ្នាំ 2012

**មីនា**

**13-14:** តេស្តHSPE រៀនសរសេរ

**15:** តេស្តHSPE រៀនអាន

**ខែមករា?កុម្ភៈ**

**ចុង-ពាក់កណ្តាល:** ប្រឡងវិញ្ញាសាគណិតសាស្ត្រ EOC ឡើងវិញ

**មេសា**

**27:** ការតេស្ត MSP តាមកុំព្យូទ័រសំរាប់ថ្នាក់ទី 3-8 ចាប់ផ្តើម

**ឧសភា**

**ឧសភា18:** ការតេស្ត MSP ចប់ (លើក្រដាស)

**មិថុនា4:** ការតេស្ត MSP ចប់ (តាមអ៊ិនធឺណិត)

**ដំណាច់ឆ្នាំ** តេស្តHS EOC គណិតសាស្ត្រ (3 អាទិត្យចុងក្រោយនៃឆ្នាំសិក្សា)

**មិថុនា**

**មិថុនា1:** ការចុះឈ្មោះសម្រាប់ការប្រឡងតេស្តHSPE ខែសីហា

**នៅ10:** របាយការណ៍ស្តីអំពីពិន្ទុនៃតេស្តHSPE ផ្ញើទៅផ្ទះសំរាប់ថ្នាក់ទី10-12

**នៅ17:** ការប្រកាសចេញលទ្ធផលតេស្តHSPE ទូទាំងរដ្ឋ

**សីហា**

**14-16:** ការប្រឡងHSPE ខែសីហា

**ចុងខែ:** ការប្រកាសចេញលទ្ធផលតេស្តMSP/HSPE សម្រាប់សិស្សទាំងអស់

**កញ្ញា**

**កណ្តាលខែ:** របាយការណ៍តេស្តMSP/HSPE ផ្ញើទៅផ្ទះ (គ្រប់ថ្នាក់ទាំងអស់)

## តើពិន្ទុតេស្ត MSP/HSPE មានន័យយ៉ាងម្តេច?

សិស្សនឹងទទួលបានពិន្ទុសម្រាប់តេស្ត MSP/HSPE នីមួយ ដែលពួកគេបានប្រឡង។ ពិន្ទុផ្អែកលើសមត្ថភាពដែលសិស្សម្នាក់ៗបានបញ្ចេញក្នុងពេលប្រឡង។ ពិន្ទុត្រូវបានចែកចេញជាបួនកម្រិត (four levels) (ដែលពិន្ទុចាប់ពីកម្រិត3 (Level 3) ឡើងទៅគឺជាពិន្ទុជាប់)៖

កម្រិត **4** **ល្អលើសបទដ្ឋានរបស់រដ្ឋ ៖** តំណាងចំណេះចំណានខ្ពស់លើជំនាញ និងតម្រិះវិជ្ជានៃប្រធានបទនីមួយៗ។

កម្រិត **3** **ជួបតាមបទដ្ឋានរបស់រដ្ឋ៖** តំណាងចំណេះចំណានលើជំនាញ និងតម្រិះវិជ្ជានៃប្រធានបទនីមួយៗ។

កម្រិត **2** **ក្រោមបទដ្ឋានរបស់រដ្ឋ៖** តំណាងចំណេះចំណានខ្លះលើជំនាញ និងតម្រិះវិជ្ជានៃប្រធានបទនីមួយៗ។

កម្រិត **1** **ក្រោមឆ្ងាយពីបទដ្ឋានរបស់ រដ្ឋ៖** តំណាងចំណេះចំណានតិចតួចបំផុត ឬក៏សូន្យលើជំនាញ និងតម្រិះវិជ្ជានៃប្រធានបទនីមួយៗ។

**បានធ្វើបច្ចុប្បធ្វើបច្ចុប្បន្នភាពក្នុងខែ កក្កដា ឆ្នាំ 2011**

# ការប្រឡងតេស្តរបស់រដ្ឋ៖ សំណួរដែលគេសួរជាញឹកញាប់

## ហេតុអ្វីបានជាយើងត្រូវតែប្រឡងតេស្តរបស់រដ្ឋ?

ពីព្រោះច្បាប់រដ្ឋនិងសហព័ន្ធតម្រូវឲ្យធ្វើដូច្នោះ។ ប្រព័ន្ធវាយតម្លៃរបស់រដ្ឋយើងបានត្រូវរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹង Education Reform Law of 1993 (ច្បាប់កែទម្រង់ប្រព័ន្ធសិក្សាអប់រំឆ្នាំ 1993) របស់រដ្ឋ។ តេស្តរបស់រដ្ឋយើងក៏អនុវត្តតាមច្បាប់ No Child Left Behind (NCLB) Act ផងដែរ។ ច្បាប់ NCLB តម្រូវឲ្យយើងធ្វើការវាយតម្លៃមើលអំពីកម្រិតតម្រិះវិជ្ជារបស់សិស្សថ្នាកទី 3-8 និងសិស្សមធ្យមសិក្សាទុតិយភូមិលើមុខវិជ្ជារៀនអាន និងគណិតសាស្ត្រជារៀងរាល់ឆ្នាំ។ សិស្សបីថ្នាក់ទៀតក៏ត្រូវតែប្រឡងតេស្តលើមុខវិជ្ជាវិទ្យាសាស្ត្រផងដែរ។ រដ្ឋវ៉ាស៊ីនតោនតម្រូវឲ្យសិស្សបីថ្នាក់នេះ ដែលរួមមានថ្នាក់ទី 5, 8 និងទី 10 ត្រូវតែប្រឡងវិញ្ញាសាលើមុខវិជ្ជានេះ។

## តើគ្រួសាររបស់សិស្សអាចទទួលបានលទ្ធផលសម្រាប់ការប្រឡងតេស្តមធ្យមសិក្សាទុតិយភូមិ របស់រដ្ឋនៅពេលណា?

នៅដើមខែមិថុនា ។ សិស្សនឹងទទួលបានពិន្ទុពីការប្រឡង HSPE សម្រាប)វិញ្ញាសារ អាននិងសរសេរ នៅខែមិថុនា 2012។ ពិន្ទុសំរាប់ការប្រឡងវិញ្ញាស ារគណិតសាស្ត្រ និងវិទ្យាសាស្ត្រ ដើម្បីបញ្ចប)ថ្នាក់នឹងមិនត្រូវបានប្រកាសរហូតដល់ខែសីហា ឆ្នាំ 2012 ។ សូមអានព័ត៌មានបន្ថែមខាងក្រោម ស្តីពី កម្មវិធីថ្មីនៃការប្រឡងវិញ្ញាគណិតសាស្ត្រដើម្បីបញ្ចប់ថ្នាក) ។

## តើគ្រួសាររបស់សិស្សអាចទទួលបានលទ្ធផលសម្រាប់ការប្រឡងតេស្ត(MSP) សម្រាប់ថ្នាក់ទី3-8 នៅពេលណា?

ពីដើមខែរហូតដល់ពាក់កណ្តាលខែកញ្ញា។ របាយការណ៍ពិន្ទុរបស់សិស្សនឹងត្រូវគេផ្ញើទៅកាន់មណ្ឌលសិក្សាធិការនីមួយៗ ក្នុងខែសីហា។ បន្ទាប់មក មណ្ឌលសិក្សាធិការនឹងត្រូវទទួលខុសត្រូវក្នុងការផ្ញើរបាយការណ៍ពិន្ទុ ទៅជូនគ្រួសាររបស់សិស្ស។ បើលោកអ្នកមិនបានទទួលរបាយការណ៍ពិន្ទុណាមួយទេ, សូមទាក់ទងទៅសាលារៀន ឬមណ្ឌលសិក្សាធិការរបស់កូនលោកអ្នក។

## តើវិញ្ញាសាប្រឡងបញ្ចប់ការសិក្សាមុខវិជ្ជាគណិតសាស្ត្រជាអ្វី ហើយតើវានឹងត្រូវគេឲ្យសិស្សប្រឡងនៅពេលណា?

វិញ្ញាសាប្រឡងគណិតសាស្ត្រថ្នាក់បញ្ចប់ថ្នាក) ឬ EOC មានពិជគណិតទី 1 និងរេខាគណិត ហើយនិងវិទ្យាសាស្ត្រ EOC មានជីវវិទ្យា។ សិស្សណាដែលប្រឡងវិញ្ញាសាពិជគណិត 1 និងរេខាគណិត ឬជីវវិទ្យាសាស្ត្រ ចាប់ពីថ្នាក់ទី 7ឡើងទៅ, នឹងប្រឡង EOC សមស្របមួយ។ ការប្រឡង EOC នឹងត្រូវបានផ្តល់ជូនក្នុងរយៈពេលបីសប្តាហ៍ចុងក្រោយបង្អស់ នៃឆ្នាំសិក្សា។ សិស្សក្នុងឆ្នាំសិក្សា 2015 តទៅត្រូវតែប្រឡងជាប់វិញ្ញាសាគណិតសាស្ត្រ EOC ទាំងពីរដើម្បីបញ្ចប់ថ្នាក) ។

## វិញ្ញាសាMSP និងវិញ្ញាសាHSPE មានទម្រង់ខ្លីជាងមុន, ប៉ុន្តែតើវាងាយស្រួលជាងមុនឬទេ?

ទេ។ គឺដូចជាឆ្នាំ 2010 ដែរ, នៅពេលរដ្ឋវ៉ាស៊ីនតោនឆ្នាំ 2011 លទ្ធផល ប្រឡងMSP និង HSPE មិនបានបង្ហាញភាពកើនឡើងច្រើននៃពិន្ទុទេ។ ការប្រឡងនៅតែបន្តមានសុពលភាព និងជារង្វាស)អាចទុកចិត្តបាននៃសកម្មភាពជាក)ស្តែងរបស)សិស្ស ។ ការប្រឡងរយៈខ្លីជាងមុន មិនមែនមានន័យថា វាងាយស្រួលជាងមុនទេ ។

## ការប្រឡងតេស្តតាមបណ្តាញអ៊ីនធឺណិត

រដ្ឋ វ៉ាស៊ីនតោន មិន មែន ជា រដ្ឋ ដំបូង គេ បង្អស់ ដែល ្ន បង្កើត វិញ្ញាសា ប្រឡង តាម បណ្តាញ អ៊ីលីណិត នៅវ្គី ទេ។ ក៏ ប៉ុន្តែ វា គឺ ជា រដ្ឋ មួយ ក្នុង ចំណោម រដ្ឋ ស្សាបនិក ទាំង ប៉ុន្មានៗ។ គោល ដៅ របស់ រដ្ឋ នៅវ្គី គឺ ការ ឈាន ទៅ សម្រេច ៀ ថ្នាក់ ភាគ ច្រើន នៃ បឋម សិកប្ញា។ និង មធ្យម សិកប្ញា បឋម ភូមិ។(Middle School). ក្នុង មុខ វិជ្ជា រេឲ្យន អាន?។ គណិត វិជ្ជា?។ និង វិទ្យា សាស្ត្រ វិជ្ជា។ ប្រឡង វិញ្ញាសា ក្នុង កុំព្យូទ័រ។ នៅ គ្រប់ មណ្ឌល សិកប្ញាលីការ ទាំង អស់ ក្នុង ឆ្នាំ។ 2014ៗ

នៅ រដ្ឋវ ស្ហឹក ឈើ លាស់។ 2012, វិញ្ញាសា។ MSP នឹង ត្រូវ ដាក់ ៀ ប្រឡង តាម បណ្តាញ អ៊ីនលីណិត សម្រាប់ ថ្នាក់ ទី។ ៣។ ដល់ ទី។ ៨។ ដែល ក្នុង នៅវ្គី។ សិសប្ញ ថ្នាក់ ទី បី គឺ ជា សិសប្ញ ដែល ្ន ទទួល ៀកាស នៅវ្គី ជា លើក ដំបូងៗ។ កាល ពី ឆ្នាំ មុន?។ សិសប្ញ ថ្នាក់ ទី បួន និង ទី ្រំ ន ចាប់ ផ្តើម ប្រឡង វិញ្ញាសា តាម បណ្តាញ អ៊ីនលីណិត សម្រាប់ មុខ វិជ្ជា រេឲ្យន អាន?។ និង គណិត វិជ្ជាៗ។ ការ ស្វែង រក លទ៕ភាព ដើម្ពី ល្ងើ យ៉ាង ណា អាច ដាក់ វិញ្ញាសា តែង សេចក្តី។ ៀ ប្រឡង តាម បណ្តាញ អ៊ីនលីណិត សម្រាប់ ថ្នាក់ ទី បួន និង ទី ្រំពី។ កំពុង ត្រូវ ្ន សិកប្ញាៗ

## តើខ្ញុំត្រូវចុះឈ្មោះកូនរបស់ខ្ញុំសម្រាប់ការប្រឡងវិញ្ញាសា HSPE យ៉ាងដូចម្តេច និងនៅពេលណា?

ធម្មតាការចុះឈ្មោះប្រឡងសម្រាប)ខែសីហាចាប់ផ្តើមប្រហែលជានៅថ្ងៃទី1 ខែមិថុនា។ អ្នកអាចចុះឈ្មោះប្រឡងនៅរដ្ឋវក្តៅតាមវិបសាយ www.k12.wa.us/testregistration ឬទូរស័ព្ទលេខ (866) 400-9275 ។ ការប្រឡង EOC ឡើងវិញនឹងប្រព្រឹត្តិទៅនៅខែមករា/កុម្ភៈរៀងរាល់ឆ្នាំ ។

## តើការប្រឡងអ្វីខ្លះដែលមានតាមអ៊ីនធឺណិត?

នៅរដ្ឋវស្លឹកឈើលាស់ ឆ្នាំ 2012, រដ្ឋនឹងផ្តល់ការប្រឡងវិញ្ញាអំនាន និង គណិតសាស្ត្រ MSP តាមអ៊ីនធឺណិតសំរាប់ថ្នាក់ទី 3-8 និងវិញ្ញាវិទ្យាសាស្ត្រ MSP សំរាប់ថ្នាក់ទី 5 និងទី 8 ។

## តើកូនប្រុសឬស្រីរបស់ខ្ញុំនៅតែត្រូវប្រឡងផ្នែករដ្ឋជាប) ទើបអាចបញ្ចប់ការសិក្សាកម្រិតវិទ្យា ល័យមែនដែរឬទេ?

ត្រឹមត្រូវហើយ។ ថ្នាក់នីមួយៗមានលក្ខណ្ឌតម្រូវផ្សេងៗគ្ន។ សូមសួរពិភាក្សាជាមួយ អ្នកផ្តល)ប្រឹក្សាអំពីការសិក្សារបស់អ្នក។

## តើតេស្តរបស់រដ្ឋមានសំណួរប្រភេទណាខ្លះ?

វិញ្ញាសាMSP និងវិញ្ញាសាHSPE មានសំណួរជាប្រភេទពហុជម្រើស និងសំណួរចម្លើយខ្លីៗ។ ការឲ្យពិន្ទុចំនួនបួនពិន្ទុទៅលើការតែងសេចក្តីត្រូវបានលុបចេញពីមុខវិជ្ជារៀនអាន, គណិតសាស្ត្រ, និងវិទ្យាសាស្ត្រហើយ។ ការផ្លាស់ប្តូរនេះគឺដើម្បីអនុញ្ញាតឲ្យសិស្សបង្ហាញថា ពួកគេមានសមត្ថភាពអាចដោះស្រាយចំណោទបញ្ហាលើតេស្តក្នុងមុខវិជ្ជារៀនអាន, គណិតសាស្ត្រ, និងវិទ្យាសាស្ត្របាន ដោយគ្មានការភ័យខ្លាចអំពីការបានឬមិនបានពិន្ទុល្អ។

## ចាត់ទុកការប្រឡងតេស្តរបស់រដ្ឋជាទស្សវិស័យ

សិស្ស និងមាតាបិតារបស់សិស្សអាចមានអារម្មណ៍យល់ថា ខ្លួនកំពុងស្ថិតក្រោមការគាបសង្កត់ដោយតេស្តរបស់រដ្ឋ, ប៉ុន្តែសូមកុំឲ្យគិតថាតេស្តនេះគឺអាទិភាពតែមួយគត់សម្រាប់ការសិក្សាអប់រំឲ្យសោះ។ អាទិភាពពិតប្រាកដនោះគឺជាជំនាញការ និងតម្រិះវិជ្ជាជារួម។

- សូមលើកទឹកចិត្តឲ្យកូនរបស់លោកអ្នកខិតខំសិក្សា។ បើសិនជាពិន្ទុរបស់កូនលោកអ្នកបង្ហាញថា កូនរបស់លោកអ្នកត្រូវការជំនួយបំប៉នក្នុងមុខវិជ្ជាសិក្សាណាមួយ, នោះវាមិនមែនជាការមិនល្អទេ។ សាលារៀនអាចជួយរកជំនួយ ដើម្បីជួយបំប៉នការសិក្សាអប់រំជូនកូនលោកអ្នកបាន។
- នៅថ្ងៃធ្វើតេស្ត, សូមលោកអ្នកជម្រុញឲ្យកូនធ្វើតាមទម្លាប់ល្អៗ ដែលធ្លាប់មានប្រសិទ្ធភាពរួមមកហើយ។ លើកលែងតែលោកអ្នកគិតថាកូនរបស់លោកអ្នកត្រូវការទម្លាប់ខុសប្រក្រតីថ្មីណាមួយ (ដូចជាការគេងឲ្យបានច្រើន ឬការធ្វើសកម្មភាពហាត់ប្រាណឲ្យបានច្រើន ។ល។)។ បើពុំនោះទេ សូមជួយលើក ទឹកចិត្តឲ្យពួកគេរក្សាទម្លាប់ល្អ ដើម្បីជួយឲ្យពួកគេទទួលបានជោគជ័យក្នុងការសិក្សាអប់រំ។
- សូមនិយាយជាមួយកូនលោកអ្នក ដើម្បីស្វែងយល់អំពីបទពិសោធនៃការធ្វើតេស្តរបស់ពួកគេ។ សិស្សខ្លះយល់ឃើញថា ដើម្បីជួយពួកគេឲ្យធ្វើតេស្តកបានល្អ, ពួកគេចូលចិត្តនិយាយអំពីតេស្តរបស់ពួកគេ។ បើកូនលោកអ្នកនិយាយប្រាប់លោកអ្នកថា ពួកគេមានបញ្ហាលំបានធ្វើតេស្តក្នុងផ្នែកណាមួយ, សូមលោកអ្នកប្រញាប់ប្រញាល់និយាយជាមួយគ្រូរបស់កូនលោកអ្នកភ្លាម ដើម្បីស្វែងយល់ឲ្យដឹង ថាតើគ្រូមានបានសម្គាល់ឃើញថា កូនលោកអ្នកមានបញ្ហាបែបនោះនៅក្នុង ថ្នាក់ដែរឬទេ។

## តើខ្ញុំអាច...

### តើអាចពិនិត្យមើលពិន្ទុនៃការប្រឡងតេស្តរបស់កូនខ្ញុំដោយរបៀបណា?

មាតាបិតារបស់សិស្សអាចស្នើសុំពិនិត្យមើលកូនសៀវភៅតេស្តរបស់កូនៗរបស់ពួកគេបាន ចាប់ផ្តើមពីថ្ងៃទី6 ខែកញ្ញា ឆ្នាំ2011 តទៅ។ កូនសៀវភៅតេស្តនេះនឹងត្រូវគេផ្ញើទៅកាន់មណ្ឌលសិក្សាធិការនីមួយ ដើម្បីពិនិត្យមើល។ សូមចូលទៅអានមើលព័ត៌មានលើគេហទំព័រ៖ www.k12.wa.us/assessment/StudentRecordRequest.aspx ។

### តើអាចប្តឹងឧទ្ធរណ៍ពិន្ទុនៃការប្រឡងតេស្តរបស់កូនខ្ញុំដោយរបៀបណា?

មានតែពន្ទុមកពីការប្រឡងសម្បទាមធ្យមសិក្សាទុតិយភូមិប៉ុណ្ណោះ ដែលត្រូវប្រើដើម្បីបំពេញតាមលក្ខខ័ណ្ឌតម្រូវសំរាប់បញ្ចប់ការសិក្សាទេ ដែលអាចយកមកប្តឹងសារទុក្ខបាន។ ពិន្ទុសំរាប់ការប្រឡងតេស្តរង្វាស)នៃការចម្រើនលូតលាស់របស់សិស្ស សម្រាប)សិស្សថ្នាក)ទី 3-8 មិនយកមកប្តឹងសារទុក្ខបានទេ។ សូមទស្សនាមើលវិបសាយ ៖ www.k12.wa.us/assessment/Appeals.aspx ។

Office of Superintendent of Public Instruction
Old Capitol Building
P.O. Box 47200
Olympia, WA 98504-7200

សម្រាប់ព័ត៌មានពិស្តារបន្ថែមស្តីពី
OSPI ៖ www.k12.wa.us
MSP/HSPE ៖ www.WAtesting.com
សំណួរ ៖ StateTesting@k12.wa.us